# ការឆាប់ធ្វើអន្តរាគមន៍

## ឯកសារយោងពីការណែនាំ សម្រាប់ការប្តូរទៅកាន់ថ្នាក់មត្តេយ្យ

នេះជាឯកសារយោងសម្រាប់មាតាបិតារបស់សិស្សពិការ ដែលមានសិទ្ធិប្តូរទៅថ្នាក់មត្តេយ្យ (ដែលមានថ្ងៃកំណើត នៅថ្ងៃ ឬ មុនថ្ងៃ ទី១ ខែកញ្ញា ឆ្នាំ២០១៥)។

**ជំហានទីមួយ**

***សាកសួរ*** អង្គការ ឬ អ្នកចាត់ចែងការបម្រើនៅ Elwyn របស់កូនលោកអ្នក អំពីការចុះឈ្មោះចូលរៀនថ្នាក់មត្តេយ្យ។ អង្គការ ឬ អ្នកចាត់ចែងការបម្រើនៅ Elwyn របស់កូនលោកអ្នក ត្រូវផ្តល់ជូនលោកអ្នកនូវលិខិត **មានបំណងចង់ចុះឈ្មោះ**។

លិខិត មានបំណងចង់ចុះឈ្មោះ គឺជាឯកសារដែលអាចឲ្យ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា ឬ សាលាឆាធ័រ ដឹងថាលោកអ្នក៖

- **ចង់**ចុះឈ្មោះកូនក្នុងកម្មវិធីថ្នាក់មត្តេយ្យ
- **មិនចង់**ចុះឈ្មោះកូននៅ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា ឬ សាលាឆាធ័រ
- **ចង់បានពេលមួយឆ្នាំថែមទៀត** ដើម្បីទទួលការបម្រើពីអង្គការ Elwyn

បើសិនជាលោកអ្នកចុះហត្ថលេខាលើលិខិតមានបំណងចង់ចុះឈ្មោះ ហើយ**ចង់ចុះឈ្មោះ**កូនលោកអ្នកនៅ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា ឬ សាលាឆាធ័រ គេតម្រូវឲ្យលោកអ្នកទៅចូលរួមជួបប្រជុំផ្ទាល់។

**ជំហានទីពីរ**

**ចូលរួម**ជួបប្រជុំផ្ទាល់ បានត្រូវគេរៀបចំសម្រាប់អង្គការរបស់កូនលោកអ្នក។ នៅក្នុងជួបប្រជុំផ្ទាល់ លោកអ្នកនឹងជួបជាមួយអ្នកតំណាងដែលមកពី ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា ឬ សាលាឆាធ័រ។ នៅក្នុងជួបប្រជុំផ្ទាល់ អ្នកតំណាងនឹងពិភាក្សាអំពី៖

- គម្រោងការសិក្សាផ្ទាល់ខ្លួន (IEP) របស់កូនលោកអ្នក
- ការអនុញ្ញាតឲ្យវាយតម្លៃជាថ្មីម្តងទៀត
- ការចុះឈ្មោះសម្រាប់ថ្នាក់មត្តេយ្យ

គេនឹងផ្តល់ព័ត៌មានជូនលោកអ្នក មានរួមទាំង **ពេលវេលា** និង **ទីកន្លែង** ដើម្បីចុះឈ្មោះសម្រាប់ថ្នាក់មត្តេយ្យ។

**ជំហានទីបី**

**ចុះឈ្មោះ**កូនលោកអ្នកនៅសាលារបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា ឬ សាលាឆាធ័រ តាមតំបន់ដែលគេបានចាត់តាំង ចាប់ផ្តើមនៅ **ថ្ងៃទី២០ ខែមករា**។ នៅពេលដែលលោកអ្នកទៅចុះឈ្មោះកូននៅសាលាដែលគេបានចាត់តាំង **សូមធ្វើតាម**ដំណាក់កាលទាំងនេះ៖

- **នាំមកជាមួយ**នូវឯកសារដូចតទៅនេះ៖
  - លិខិតបញ្ជាក់ពីថ្ងៃកំណើតរបស់ក្មេង
  - សំណុំឯកសារអំពីការចាក់ថ្នាំបង្ការរោគរបស់ក្មេង
  - ភស្តុតាងអំពីអាស័យដ្ឋាន
    - ប័ណ្ណបើកបររថយន្តនៃរដ្ឋផិនស៊ីលវេញ៉ា ឬ អត្តសញ្ញាណប័ណ្ណនៃរដ្ឋផិនស៊ីលវេញ៉ា
    - វិក័យប័ត្រ (ហ្គេស ឬ ភ្លើង)
    - កន្ទុយសែក
- ជម្រាបឲ្យអ្នកដែលលោកអ្នកនិយាយជាមួយនៅសាលាដឹងថា លោកអ្នក ចុះឈ្មោះកូនសម្រាប់ថ្នាក់មត្តេយ្យ ហើយកូនលោកអ្នកទទួលការបម្រើផ្នែក ឆាប់ធ្វើអន្តរាគមន៍ (Early Intervention)។